# ចំពោះអ្នកកាន់ប័ណ្ណបើកបរបរទេស

## វិធីបើកបរនៅប្រទេសជប៉ុន

■ដើម្បីបើកបរនៅប្រទេសជប៉ុន ចាំបាច់កាន់ប័ណ្ណបើកបរប្រភេទណាមួយនៅក្នុងចំណោមខាងក្រោម៖

1) ប័ណ្ណបើកបរជប៉ុន

2) ប័ណ្ណបើកបរអន្តរជាតិដែលផ្អែកលើសន្ធិសញ្ញាស្តីពីការដឹកជញ្ជូនតាមផ្លូវគោក (សន្ធិសញ្ញាទីក្រុងហ្សឺណែវ ១៩៤៩)

※ ក្នុងករណីវាជាប័ណ្ណបើកបរដែលមិនត្រូវបានចេញដោយប្រទេសដែលចុះសន្ធិសញ្ញាទីក្រុងហ្សឺណែវ ឬ ក្នុងករណីប្រទេសនោះបានចុះសន្ធិសញ្ញាទីក្រុងហ្សឺណែវតែមិនបានចេញប័ណ្ណបើកបរអន្តរជាតិតាមទម្រង់សន្ធិសញ្ញាទីក្រុងហ្សឺណែវ គេមិនអាចបើកបរដោយប្រើប័ណ្ណបើកបរអន្តរជាតិនៃប្រទេសនោះបានទេ។

3) ប័ណ្ណបើកបរបរទេស

ប័ណ្ណបើកបររបស់ក្រៅប្រទេស※ 1 (ទទួលស្គាល់តែប័ណ្ណបើកបរដែលភ្ជាប់ការបកប្រែដោយភាសាជប៉ុនដែលត្រូវបកប្រែដោយអ្នកដែលត្រូវកំណត់ដោយអនុក្រឹតប៉ុណ្ណោះ)

※ 1 ទទួលស្គាល់តែប័ណ្ណបើកបរដែលចេញដោយប្រទេសឬតំបន់ ដែលមិនបានចេញប័ណ្ណបើកបរអន្តរជាតិ តែប្រទេសនិងតំបន់នោះ(អេស្តូនៀ ស្វីស អាល្លឺម៉ង់ បារាំង បែលហ្ស៊ិក ម៉ូណាកូ និងតៃវ៉ាន់ (គិតត្រឹមថ្ងៃទី ១ ខែមីនាឆ្នាំ ២០២០ ។ សម្រាប់ស្ថានភាពចុងក្រោយ សូមបញ្ជាក់តាមមជ្ឈមណ្ឌលផ្តល់ប័ណ្ណបើកបរតាមថ្នាក់ខេត្ត) មានប្រព័ន្ធប័ណ្ណបើកបរដែលមានស្តង់ដារប្រហែលនឹងប្រទេសជប៉ុនប៉ុណ្ណោះ។

※ 2 អ្នកដែលត្រូវកំណត់ដោយអនុក្រឹតថាជាអ្នករៀបចំពាក្យបកប្រែជាភាសាជប៉ុនគឺមានដូចខាងក្រោម។ មិនត្រូវរួមបញ្ចូលនូវអ្នកបកប្រែកំណត់ដោយច្បាប់នៅបរទេសឡើយ។

1) ស្ថាប័នរដ្ឋបាលបរទេសដែលមានសិទ្ធិចេញប័ណ្ណបើកបរ ឬស្ថាប័នកុងស៊ុលនៃប្រទេសនោះ (ស្ថាប័នចេញប័ណ្ណបើកបរនៃបរទេសឬស្ថានទូត・ស្ថានកុងស៊ុលប្រចាំជប៉ុននៃប្រទេសនោះ)

2) នីតិបុគ្គលឬជនដទៃណាដែលស្ថាប័នរដ្ឋបាលនៃបរទេសដែលទទួលបន្ទុកបទបញ្ញត្តិទាក់ទងនឹងច្បាប់ចរាចរណ៍ផ្លូវគោក (សម្រាប់តែផ្នែកដែលទាក់ទងនឹងប័ណ្ណបើកបរ) បានជូនដំណឹងថាជាអ្នកមានសមត្ថភាពរៀបចំពាក្យបកប្រែជាភាសាជប៉ុនលើប័ណ្ណបើកបរនៃបរទេសនោះ ទៅអោយគណៈកម្មការសន្តិសុខជាតិ ហើយគណៈកម្មការសន្តិសុខជាតិបានទទួលស្គាល់ថាសមរម្យ (សព្វថ្ងៃនេះគេបានទទួលស្គាល់លើសមាគមពាក់ព័ន្ធជប៉ុននៃតៃវ៉ាន់សម្រាប់ប័ណ្ណបើកបរតៃវ៉ាន់ និងសហព័ន្ធយានយន្តអាល្លឺម៉ង់សម្រាប់ប័ណ្ណបើកបរអាល្លឺម៉ង់)។

3) អ្នកដែលគណៈកម្មការសន្តិសុខជាតិបានកំណត់ដោយទទួលស្គាល់ថា អាចរៀបចំយ៉ាងត្រឹមត្រូវនិងពិតប្រាកដនូវពាក្យបកប្រែជាភាសាជប៉ុនលើប័ណ្ណបើកបរ ដែលពាក់ព័ន្ធនឹងអាជ្ញាប័ណ្ណនៃស្ថាប័នរដ្ឋបាលបរទេស ដែលពាក់ព័ន្ធនឹងយានយន្ត (សព្វថ្ងៃនេះ JAF (JAPAN AUTOMOBILE FEDERATION) ត្រូវបានកំណត់)។

■រយៈពេលដែលអាចបើកបរនៅប្រទេសជប៉ុនបាន

1) ប័ណ្ណបើកបរជប៉ុន : ក្នុងអំឡុងពេលសុពលភាពដែលត្រូវកត់ត្រានៅលើប័ណ្ណបើកបរជប៉ុន

2) ប័ណ្ណបើកបរអន្តរជាតិនិងប័ណ្ណបើកបរបរទេស : ក្នុងអំឡុងពេលណាមួយខ្លីជាងរវាង ក្នុង១ឆ្នាំចាប់ពីថ្ងៃដែលមកដល់ទឹកដីជប៉ុន ឬក្នុងកំឡុងពេលសុពលភាពនៃប័ណ្ណបើកបរនោះ (ក៏ប៉ុន្តែ ក្នុងករណីជនដែលត្រូវកត់ត្រានៅក្នុងសៀវភៅមូលដ្ឋានពលរដ្ឋ ត្រូវបានបញ្ជាក់ពីការចាកចេញពីប្រទេស ឬត្រូវបានទទួលការអនុញ្ញាតចូលប្រទេសម្តងទៀតរួចហើយចេញពីប្រទេសជប៉ុន ហើយបានត្រឡប់មកវិញក្នុងអំឡុងពេលតិចជាង ៣ ខែនោះ កាលបរិច្ឆេទនៃត្រឡប់មកវិញ(ចូលទឹកដី)នោះ មិនមែនជាថ្ងៃដែលគិតរាប់អំឡុងពេលដែលអាចបើកបរដោយប័ណ្ណបើកបរអន្តរជាតិឡើយ)។

※ ចំពោះរយៈពេលដែលអាចបើកបរដោយប័ណ្ណបើកបរអន្តរជាតិនោះ សូមមើលរូបដោយឡែក។

## វិធីទទួលប័ណ្ណបើកបរជប៉ុន

■ចំពោះអ្នកដែលបានកាន់ប័ណ្ណបើកបរនៅបរទេសជាដើម

① ចំណេះដឹងពាក់ព័ន្ធនឹងវិធីចរាចរណ៍ផ្លូវថ្នល់ឬការបើកបរយានយន្តផ្សេងទៀតជាដើម

② បទពិសោធន៍បើកបរនូវយានយន្តជាដើម

③ ជំនាញពាក់ព័ន្ធនឹងការបើកបរនូវយានយន្តជាដើម

ក្នុងករណីគណៈកម្មការសន្តិសុខជាតិថ្នាក់ខេត្តបានបញ្ជាក់ពីប្រការខាងលើ ប្រឡងសរសេរនិងប្រឡងជំនាញនៅប្រទេសជប៉ុនត្រូវបានលើកលែង ហើយអាចទទួលប័ណ្ណបើកបរជប៉ុនដែលទាក់ទងនឹងយានយន្តដែលអាចបើកបរបានដោយប័ណ្ណបើកបររបស់បរទេសនោះជាដើម។

ម្យ៉ាងទៀត អ្នកដែលកាន់ប័ណ្ណបើកបរបរទេសដែលមានប្រព័ន្ធប័ណ្ណបើកបរដែលត្រូវទទួលស្គាល់ថាមានស្តង់ដារប្រហែលនឹងជប៉ុន (※) នោះ ក៏ត្រូវលើកលែងនូវការបញ្ជាក់ពីចំណេះដឹងនិងជំនាញផងដែរ។

※ អ៊ីស្លង់ អៀរឡង់ សហរដ្ឋអាមេរិក (មានកំណត់ចំពោះតែរដ្ឋ វិជីនៀ, ហាវ៉ៃ, ម៉ារីឡេន និង វ៉ាស៊ីនតោន) ចក្រភពអង់គ្លេស អ៊ីតាលី អូស្ត្រាលី អូទ្រីស ហូឡង់ កាណាដា កូរ៉េ ក្រិក ស្វ៊ីស ស៊ុយអែត អេស្ប៉ាញ ស្លូវេនី សាធារណរដ្ឋឆែក ដាណឺម៉ាក អាឡឺម៉ង់ ញូហ្សេលឡែន ន័រវែស ហុងគ្រី ហ្វាំងឡង់ បារាំង ប៊ែលហ្សិក ប៉ូឡូញ ព័រទុយហ្កាល់ ម៉ូណាកូ លុចសំបួ តៃវ៉ាន់ សរុប ២៩ ប្រទេស / តំបន់ (គិតត្រឹមថ្ងៃទី ១ ខែមីនា ឆ្នាំ ២០២០) ។ សូមបញ្ជាក់តាមមជ្ឈមណ្ឌលផ្តល់ប័ណ្ណបើកបរតាមថ្នាក់ខេត្ត។ )

■កន្លែងដាក់ពាក្យ

មជ្ឈមណ្ឌលប័ណ្ណបើកបរនៅស្នងការនគរបាលខេត្តនៅតាមកន្លែងស្នាក់នៅនៅជប៉ុនជាដើម

■កំណត់សំគាល់

1) មានលក្ខខណ្ឌដែលថាបន្ទាប់ពីបានទទួលប័ណ្ណបើកបរបរទេសហើយ ត្រូវស្នាក់នៅសរុបលើស ៣ ខែឡើងនៅប្រទេសជាដើមនោះ (ចាំបាច់មានឯកសារដែលបញ្ជាក់ពីអំឡុងពេលស្នាក់នៅ ដែលមានដូចជាលិខិត

ឆ្លងដែនដែលមានវាយត្រាអន្តោប្រវេសន៍ជាដើម)។

2) មិនត្រូវអនុញ្ញាតិដាក់ពាក្យដោយអ្នកតំណាងឡើយ។ ដាច់ខាតត្រូវដាក់ពាក្យដោយសាមីខ្លួន។

■ឯកសារដែលចាំបាច់នៅពេលដាក់ពាក្យប័ណ្ណបើកបរ

1) លិខិតពាក្យសុំ

※ ស្របជាមួយលិខិតពាក្យសុំ ចាំបាច់ដាក់ "ប័ណ្ណសំនួរ" ស្តីអំពីស្ថានភាពជម្ងឺជាដើម (ឆ្លើយតបនូវភាសាបរទេសចំនួន ១១ ដូចជាភាសាអង់គ្លេស ភាសាចិនជាដើម)។ ក្នុងករណីខ្លួនមានអាការៈត្រូវនឹង ប្រការសំនួរណាមួយនោះ មន្ត្រីនឹងចុះទៅសាកសួរពីស្ថានភាពអាការៈនោះ។

2) រូបថតសម្រាប់ពាក្យសុំ ១ សន្លឹក

※ រូបថតដែលត្រូវបានថតនៅអំឡុងពេល ៦ ខែមុនដាក់ពាក្យ ដែលគ្មានពាក់មួក (ចំពោះជនណាដែលមានហេតុផលផ្នែកសាសនាឬវេជ្ជសាស្ត្រ អនុញ្ញាតិអោយគ្របក្បាលដោយក្រណាត់ក្នុងក្របខណ្ឌធ្វើយ៉ាងណាអាចដឹងពីរូបរៀងនៃផ្ទៃមុខបាន) បែរមុខត្រង់ គ្មានរូបភាពនៅខាងក្រោយខ្លួន ព្រមទាំងថតចាប់ពីដើមទ្រូងឡើង។ ទំហំ 3.0×2.4 cm ។ កត់ត្រាឈ្មោះនិងកាលបរិច្ឆេទនៃការថតនៅផ្ទៃខាងក្រោយ។

3) លិខិតចម្លងប័ណ្ណស្នាក់នៅដែលមានការកត់ត្រានូវស្រុកកំណើតដើម (ចំពោះអ្នកដែលមិនតម្រូវអោយចុះនៅសៀវភៅមូលដ្ឋានពលរដ្ឋគឺលិខិតឆ្លងដែនជាដើម)

4) ប័ណ្ណអ្នកទទួលធានារ៉ាប់រងនៃធានារ៉ាប់រងសុខភាព ប័ណ្ណលេខផ្ទាល់ខ្លួន ប័ណ្ណស្នាក់នៅជនបរទេសជាដើម (ត្រូវបង្ហាញ)

5) ប័ណ្ណបើកបរបរទេសជាដើម (មិនអនុញ្ញាតិអោយក្នុងករណីមានតែប័ណ្ណបើកបរអន្តរជាតិឡើយ)

6) ពាក្យបកប្រែជាភាសាជប៉ុនលើប័ណ្ណបើកបរខាងលើ (ត្រូវរៀបចំឡើងដោយអ្នកដែលត្រូវកំណត់តាមអនុក្រឹត（P1※2）ហើយត្រូវបញ្ជាក់ពីប្រភេទយានយន្តដែលអាចបើកបរបានដោយប័ណ្ណបើកបរនោះ រយៈពេលសុពលភាពនៃប័ណ្ណបើកបរ លក្ខខណ្ឌនៃប័ណ្ណបើកបរនោះ។)

7) ឯកសារដែលអាចបញ្ជាក់ថាបន្ទាប់ពីបានទទួលប័ណ្ណបើកបរនោះ ធ្លាប់បានស្នាក់នៅសរុប ៣ ខែឡើងនៅបរទេសជាដើមនោះ ដែលមានដូចជាលិខិតឆ្លងដែនដែលមានវាយត្រាអន្តោប្រវេសន៍ជាដើម

8) ថ្លៃសេវាកម្ម

■ផ្សេងៗ

ចំពោះការពិគ្រោះយោបល់ស្តីពីជម្ងឺឬពិការភាពជាដើម ត្រូវទទួលដោយកន្លែងទំនាក់ទំនងស្តីពីសុវត្ថិភាពបើកបរនៅស្នងការនគរបាលថ្នាក់ខេត្តនានាជាដើម។

ចំពោះព័ត៌មានស្តីពីទីកន្លែងឬម៉ោងទទួលពាក្យសុំ ឯកសារដែលចាំបាច់សម្រាប់ពាក្យសុំ ព័ត៌មានលំអិតស្តីពីថ្លៃសេវាកម្មជាដើមនោះ សូមទំនាក់ទំនងមជ្ឈមណ្ឌលប័ណ្ណបើកបរនៅស្នងការនគរបាលថ្នាក់ខេត្ត ដែលខ្លួនដាក់ពាក្យ។

# រយៈពេលដែលអាចបើកបរដោយប័ណ្ណបើកបរអន្តរជាតិ

## 1 ក្នុងករណីអ្នកដែលមិនបានចុះនៅសៀវភៅមូលដ្ឋានពលរដ្ឋមកដល់ទឹកដីជប៉ុន

### (1) ក្នុងករណីមកដល់ទឹកដីជាលើកដំបូងបន្ទាប់ពីបានទទួលប័ណ្ណបើកបរអន្តរជាតិ




### (2) ក្នុងករណីបានទទួលប័ណ្ណបើកបរបន្ទាប់ពីបានមកដល់ទឹកដីជាលើកដំបូង




## 2 ក្នុងករណីអ្នកដែលបានចុះនៅសៀវភៅមូលដ្ឋានពលរដ្ឋបានចេញពីប្រទេសហើយមកល់ដល់ទឹកដីវិញ

### (1) ក្នុងករណីមកដល់ទឹកដីវិញដោយបានស្នាក់នៅក្រៅប្រទេសលើស៣ខែ



## (2) ក្នុងករណីមកដល់ទឹកដីវិញដោយបានស្នាក់នៅក្រៅប្រទេសតិចជាង ៣ខែ (ករណីភាគច្រើនសម្រាប់សញ្ជាតិបរទេស)




## (3) ក្នុងករណីមកដល់ទឹកដីវិញបន្ទាប់ពីបានស្នាក់នៅក្រៅប្រទេសតិចជាង ៣ខែ (ករណីភាគច្រើនសម្រាប់សញ្ជាតិជប៉ុន)

